**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:...១៩...ស.ល.ឯ.**

# សារលិខិត

# សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសខួបលើកទី៦៩ ទិវាកុមារអន្តរជាតិ ១ មិថុនា ខួបលើកទី១៧ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២ មិថុនា និងទិវាកុមារកម្ពុជា ឆ្នាំ២០១៨

*- សូមថ្វាយបង្គំសម្តេចព្រះមហាសង្ឃរាជទាំងពីរគណៈ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ*

*- សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី*

*- បងប្អូនជនរួមជាតិ និងក្មួយៗកុមារា កុមារីជាទីស្រឡាញ់ !*

ក្នុងឱកាសដ៏មហោឡារិកនៃ**ខួបលើកទី៦៩ ទិវាកុមារអន្តរជាតិ ១ មិថុនា ខួបលើកទី១៧ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២ មិថុនា និងទិវាកុមារកម្ពុជា ឆ្នាំ២០១៨** នេះ ទូលព្រះបង្គំ ខ្ញុំព្រះករុណាខ្ញុំ ក្នុងនាមរាជរដ្ឋាភិបាល និងក្នុងនាមប្រធានកិត្តិយសក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ សូមសម្តែងនូវមនោសញ្ចេតនារីករាយ និងគាំទ្រយ៉ាងពេញទំហឹងចំពោះការរៀបចំទិវាដ៏មានសារៈសំខាន់នេះ។ ការប្រារព្ធទិវាដ៏មានអត្ថន័យនេះគឺបង្ហាញអំពីឆន្ទៈមោះមុត និងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការបន្តលើកកម្ពស់ការអនុវត្តសិទ្ធិកុមារ និងសូមលើកទឹកចិត្តឱ្យបងប្អូនជនរួមជាតិយើងទាំងអស់ រួមគ្នាបន្តលើកស្ទួយវិស័យសុខុមាលភាពកុមារឲ្យកាន់តែល្អប្រសើរ ដើម្បីឧត្តមប្រយោជន៍របស់កុមារនៅកម្ពុជា។

ឆ្នាំនេះ ទិវាកុមារកម្ពុជា និងទិវាកុមារអន្តរជាតិ ១ មិថុនា ត្រូវបានប្រារព្ធឡើងក្រោមប្រធានបទ **"រួមគ្នាការពារកុមារ ដើម្បីអភិវឌ្ឍគ្រួសារនិងសង្គមជាតិ"** និងទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២ មិថុនា ក្រោមប្រធានបទ **"ទប់ស្កាត់គ្រោះថ្នាក់ការងារ និងភាពងាយរងគ្រោះផ្នែកសុខភាពសម្រាប់កម្មករនិយោជិតវ័យក្មេង ដើម្បីលុបបំបាត់ពលកម្មកុមារ"** ដើម្បីរំលឹកដល់សិទ្ធិជាមូលដ្ឋានរបស់កុមារ និងបង្ហាញពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល ក្នុងការដោះស្រាយបញ្ហាប្រឈមទាំងឡាយរបស់កុមារ ជាពិសេស ការពារកុមារពីការរំលោភបំពាន ពលកម្មកុមារគ្រប់ទម្រង់ ជួយគាំទ្រដល់កុមាររងគ្រោះ និងងាយរងគ្រោះបានទាន់ពេលវេលា ប្រកបដោយសុវត្ថិភាព និងមានប្រសិទ្ធភាព ព្រមទាំងរស់នៅយ៉ាងសុខដុមរមនាជាមួយគ្រួសារនៅក្នុងសង្គមដែលពោរពេញទៅដោយសន្តិភាព។

ព្រះរាជាណាចក្រកម្ពុជាកំពុងរក្សាបាននូវស្ថិរភាពនយោបាយ សុខសន្តិភាព និងសណ្តាប់ធ្នាប់សាធារណៈយ៉ាងល្អប្រសើរទូទាំងប្រទេស ដែលកត្តានេះបានបង្កលក្ខណៈងាយស្រួលដល់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍសង្គមជាតិ ដើម្បីគោលដៅកសាងអនាគតកម្ពុជាមួយដ៏រុងរឿង ឆ្លើយតបនឹងបំណងប្រាថ្នារបស់ប្រជាជនគ្រប់វ័យ